រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

002KH01A-01

អត្ថបទសិក្សា ទី ៧

"ដំណឹងល្អបំផុត"



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ព្រះយេស៊ូគ្រីស្តបំផ្លាស់បំប្រែមនុស្សម្នាក់

ព្រះយេស៊ូ និងពួកសាវ័កបានទៅដល់ត្រើយម្ខាង ក្នុងតំបន់កេ-រ៉ាសា ។ កាលព្រះអង្គយាងឡើងពីទូកភ្លាម មានបុរសម្នាក់ខ្មោចចូលបានចេញពីទីបញ្ចុះសព ដើរតំរង់មករកព្រះអង្គ ។ បុរសនេះស្នាក់នៅតែតាមទីបញ្ចុះសព គ្មាននរណាអាចចងគាត់បានឡើយ សូម្បីតែយកច្រវាក់មកចងក៏មិនជាប់ដែរ ។ គេបានដាក់ខ្នោះជើង និងយកច្រវាក់ចងគាត់ច្រើនដង ប៉ុន្តែ គាត់នៅតែកាច់បំបាក់ច្រវាក់ និងខ្នោះទាំងនោះជានិច្ច ។ គ្មាននរណាអាចបង្ក្រាបគាត់បានឡើយ ។ គាត់រស់នៅតាមទីបញ្ចុះសព និងតាមភ្នំ ទាំងយប់ទាំងថ្ងៃ ហើយចេះតែស្រែក ព្រមទាំងយកថ្មមកអារសាច់ខ្លួនឯងថែមទៀតផង ។

កាលគាត់ឃើញព្រះយេស៊ូពីចម្ងាយ ក៏រត់មកក្រាបថ្វាយបង្គំព្រះ-អង្គ ហើយស្រែកយ៉ាងខ្លាំងថា៖ «ឱ ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ តើព្រះអង្គចង់ធ្វើអ្វីទូលបង្គំ ? ទូលបង្គំអង្វរព្រះអង្គក្នុងព្រះនាមព្រះជាម្ចាស់ សូមមេត្តាកុំធ្វើទុក្ខទោសទូលបង្គំអី ! » ។ ខ្មោចនិយាយដូច្នេះ ព្រោះព្រះយេស៊ូបានបញ្ជាវាថា៖ *«នែខ្មោចបិសាច ចូរចេញពីអ្នកនេះទៅ ! »* ។

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

ព្រះយេស៊ូមានព្រះបន្ទូលសួរទៅខ្មោចថា÷ *«ឯងឈ្មោះអី?»* ខ្មោចទូលឆ្លើយថា÷ *«ទូលបង្គំឈ្មោះកងទ័ព ដ្បិតយើងខ្ញុំមានគ្នាច្រើន»* ។ វាទទូចអង្វរ សូមកុំអោយព្រះអង្គបណ្តេញពួកវាចេញពីស្រុកនោះ ។ នៅក្បែរនោះមានជ្រូកមួយហ្វូងធំកំពុងរកស៊ី នៅតាមចង្កេះភ្នំ ។ ពួកខ្មោចអង្វរព្រះយេស៊ូថា÷ «សូមបញ្ជូនយើងខ្ញុំឱ្យទៅចូលក្នុងជ្រូកទាំងនោះទៅ !» ។

ព្រះយេស៊ូក៏យល់ព្រម ។ ខ្មោចចេញពីបុរសនោះទៅចូលក្នុងជ្រូក ។ ហ្វូងជ្រូកដែលមានចំនួនប្រមាណជាពីរពាន់ក្បាល ក៏បោលចុះតាមជំរាលភ្នំ តំរង់ទៅសមុទ្រលង់ទឹកស្លាប់អស់ ។

ពួកអ្នកថែរក្សាហ្វូងជ្រូកយករឿងនេះ រត់ទៅប្រាប់អ្នកនៅទីក្រុង និងអ្នកនៅស្រុកស្រែ មនុស្សម្នាក៏នាំគ្នាមកមើលហេតុការណ៍នោះ ។ គេចូលមករកព្រះយេស៊ូ ឃើញបុរសដែលមានខ្មោចកងទ័ពចូលកាលពីមុន អង្គុយមានសម្លៀកបំពាក់ ហើយដឹងស្មារតី នោះគេក៏នាំគ្នាកោតស្ញប់ស្ញែង ។ អស់អ្នកដែលបានឃើញផ្ទាល់នឹងភ្នែករៀបរាប់ប្រាប់គេអំពីហេតុការណ៍ ដែលកើតមានដល់បុរសនោះ និងអំពីហ្វូងជ្រូក ។

គេទូលអង្វរព្រះយេស៊ូ ឱ្យចាកចេញពីស្រុកភូមិរបស់គេ ។ ពេលព្រះអង្គកំពុងយាងចុះទូក បុរសដែលខ្មោចចូលពីមុនបានអង្វរសុំនៅជាមួយព្រះអង្គ ។ ព្រះយេស៊ូមិនយល់ព្រមទេ ផ្ទុយទៅវិញទ្រង់មានព្រះបន្ទូលថា÷ *«ចូរអ្នកត្រឡប់ទៅផ្ទះ ទៅនៅជាមួយក្រុមគ្រួសារវិញចុះ ហើយរៀបរាប់ហេតុការណ៍ទាំងប៉ុន្មាន ដែលព្រះអម្ចាស់បានប្រោសដល់អ្នក ដោយព្រះហឫទ័យអាណិតអាសូរ»* ។

បុរសនោះក៏ចេញទៅ ហើយចាប់ផ្តើមប្រកាសប្រាប់អោយប្រជាជនក្នុងស្រុកដេកាប៉ូល ជឹងអំពីការទាំងអស់ ដែលព្រះយេស៊ូបានប្រោសដល់គាត់ ។ អស់អ្នកដែលបានឮពាក្យគាត់ កោតស្ងប់ស្ងែងក្រៃលែង ។ (ម៉ាកុស ៥:១-២០) ។

តើពួកខ្មោចជឹងអំពីឫទ្ធានុភាពរបស់ព្រះយេស៊ូ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដែរឬទេ ?

☐ ជឹង ។

☐ មិនជឹងទេ ។

កំណត់ចំណាំ

© Project WorldReach © SEAN

ខ សំរាប់ទន្ទេញ

«ចរិតចាស់របស់យើងបានជាប់ឆ្កាងជាមួយព្រះអង្គរួចហើយ ដើម្បីអោយយើងលែងធ្វើជាខ្ញុំបំរើរបស់បាបតទៅទៀត » ។

(រ៉ូម ៥-៦)

កិច្ចការដែលត្រូវអនុវត្ត

- ទូលសូមព្រះវិញ្ញាណព្រះជាម្ចាស់ ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូ អោយយាងមកគង់ក្នុងជីវិតរបស់អ្នក ដើម្បីកែប្រែជីវិតរបស់អ្នក ។

- និយាយប្រាប់គ្រួសារអ្នកអំពីព្រះយេស៊ូ ដែលបានកែប្រែបុរសអ្នកស្រុកកេរ៉ាសា ដែលមានខ្មោចចូល ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

តើបុរសក្នុងរឿងនេះ មានបញ្ហាអ្វី ?

_____

_____

ព្រះអម្ចាស់យេស៊ូបញ្ជាអោយពួកខ្មោចចេញពីបុរសនោះ ។ តើពួកខ្មោចទាំងនោះចេញទៅណា ?

_____

តើបន្ទាប់មក សត្វជ្រូកទាំងនោះធ្វើអ្វី ?

_____

តើបន្ទាប់ពីខ្មោចចេញបាត់ទៅ បុរសនោះមានសភាពដូចម្តេច ?

_____

តើព្រះគ្រីស្តមានឫទ្ធានុភាពអាចកែប្រែទាំងមនុស្ស ដែលធ្លាក់ចុះខ្លាំង ដោយសារអំណាចរបស់វិញ្ញាណអាក្រក់ បានដែរឬទេ ?

☐ មាន ។

☐ មិនមានទេ ។

© Project WorldReach © SEAN

តើព្រះគ្រីស្តមានឫទ្ធានុភាពអាចកែប្រែអ្នក និងគ្រួសារអ្នកដែរឬទេ ?

☐ មាន ។

☐ មិនមានទេ ។

បុរសអ្នកស្រុកកេរ៉ាសា ដែលព្រះយេស៊ូបានកែប្រែ ចង់ជិះទូកទៅជាមួយព្រះយេស៊ូ តែព្រះអម្ចាស់ចង់អោយគាត់ធ្វើអ្វីផ្សេងវិញ ។

តើព្រះយេស៊ូប្រាប់គាត់អោយធ្វើអ្វី ?

_____

_____

បុរសនោះធ្វើតាមព្រះអម្ចាស់ ហើយនិយាយប្រាប់គ្រួសារគាត់ អំពីអ្វីៗគ្រប់យ៉ាង ដែលព្រះគ្រីស្តបានធ្វើ ។ តើអ្នកបានត្រៀមខ្លួនដើម្បីនិយាយប្រាប់គ្រួសារអ្នក និងមិត្តភក្តិរបស់អ្នក ពីអ្វីៗដែលព្រះគ្រីស្តបានធ្វើសំរាប់អ្នក ហើយឬនៅ ?

☐ ត្រៀមខ្លួនហើយ ។

☐ មិនទាន់ត្រៀមខ្លួនទេ ។

តើយើងទទួលអត្ថប្រយោជន៍អ្វី ពីការសុគតរបស់ព្រះយេស៊ូ ?

_____

_____

តើយើងទទួលអត្ថប្រយោជន៍អ្វី ពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូគ្រីស្ត ?

_____

_____

តើមនុស្សមានបាប អាចទទួលអត្ថប្រយោជន៍ទាំងពីរនេះបានដោយរបៀបណា ?

ដោយសារជំ _____ ។

តើព្រះជាម្ចាស់ចង់អោយអ្នកកែប្រែដូចម្តេច ?

_____

តើមនុស្សបាបដែលទន់ខ្សោយ អាចកែប្រែឡើងវិញបាន ដោយសារឫទ្ធានុភាពរបស់នរណា ?

_____

© Project WorldReach © SEAN